ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ៣៧៩ ក.ណ..គ.ព.ទ.ប្រក

ភ្នំពេញ. ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ១៩៩..៩

# ប្រកាស
## ស្តីពី
## វិធានការចំពោះផលិតផលម្ហូបអាហារ ដែលមានផ្លាកសញ្ញាពុំសមស្របតាមបទប្បញ្ញត្តិជាធរមាន

## រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
_បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
_បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២នស_៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
_បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
_បានឃើញប្រកាសលេខ ០១២ពណ.បល.ប្រក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ_អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ
_ដើម្បីការពារសុខភាព សុវត្ថិភាពរបស់អ្នកប្រើ និងធានារបៀបរៀបរយក្នុងទីផ្សារ
_យោងទៅលើស្ថានភាពជាក់ស្តែងនាបច្ចុប្បន្ន

## សំ រេ ច

**ប្រការ១:** ហាមឃាត់ការនាំចូល ការធ្វើចរាចរ ការលក់ ការដាក់លក់ ការតាំងបង្ហាញនូវផលិតផលម្ហូបអាហារដែលពុំមានផ្លាកសញ្ញា ឬដែលមានផ្លាកសញ្ញាពុំត្រឹមត្រូវ ឬពុំគ្រប់តាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិជាធរមាន ដោយពុំគិតនូវគុណភាព ផ្នែកសុខភាព សុវត្ថិភាពនៃសមាសធាតុផ្ទាល់ ។

លក្ខខណ្ឌតម្រូវជាធរមាន មានជាអាទិ៖

- _ឈ្មោះមុខទំនិញ
- _ឈ្មោះ អាសយដ្ឋានរបស់អ្នកទទួលខុសត្រូវលើផលិតផល (អ្នកផលិត ឬអ្នកវេចខ្ចប់ ឬអ្នកធ្វើពាណិជ្ជកម្ម)
- _ប្រភព
- _បរិមាណ ទម្ងន់ ចំណុះ... ។ល។
- _លេខឡូត៍ និងថ្ងៃផលិត
- _ថ្ងៃផុតកំណត់នៃការប្រើប្រាស់
- _គ្រឿងផ្សំ
- _វិធីប្រើ (ប្រសិនបើចាំបាច់)
- _លិខិតអនុញ្ញាតរបស់ស្ថាប័នមានសមត្ថកិច្ចមុនដាក់អោយចរាចរ (បើមានលក្ខខណ្ឌតម្រូវ និងចំពោះផលិតផលផលិតក្នុងស្រុក) ។

ប្រការ២៖ ហាមឃាត់ការដាក់លក់តាមទីផ្សារ នូវផ្លាកសញ្ញាបោះពុម្ពស្រេច សំរាប់ផលិតផលម្ហូបអាហារជាក់លាក់ណាមួយ ។

ប្រការ៣៖ រាល់ផលិតផលម្ហូបអាហារដែលធ្វើចរាចរ ឬដាក់តាំងបង្ហាញដោយពុំមានផ្លាកសញ្ញា ឬមានផ្លាកសញ្ញាពុំគ្រប់គ្រាន់ត្រឹមត្រូវតាមបទប្បញ្ញត្តិដែលមានចែងក្នុងប្រការ១ ត្រូវប្រមូលប្រគល់អោយទៅម្ចាស់កម្មសិទ្ធិផលិតផល ដើម្បីអោយបំពេញតម្រូវតាមបទប្បញ្ញត្តិចំពោះផ្លាកសញ្ញា កាលបើគុណភាព ផ្នែកសុខភាព សុវត្ថិភាព នៃសមាសធាតុផ្សំមានលក្ខណៈសមស្រប ។ ក្នុងករណីផលិតផលម្ហូបអាហារនោះមានគុណភាពពុំសមស្រប ផលិតផល នោះត្រូវប្រមូលកំទេចចោល ឬអោយនាំចេញទៅវិញ (ចំពោះទំនិញនាំចូល) ។

ប្រការ៤៖ ម្ចាស់ផលិតផលម្ហូបអាហារដែលប្រព្រឹត្តល្មើសនឹងប្រការ១ ឬប្រការ២ នៃប្រកាសនេះ លើកទី១ ត្រូវបានព្រមានជាលាយលក្ខណ៍អក្សរ ។

ក្នុងករណីមិនរាងចាល ហើយប្រព្រឹត្តជាបន្តទៀតត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ប្រការ៥៖ អគ្គនាយកបច្ចេកទេសនៃក្រសួងពាណិជ្ជកម្ម ប្រធាននាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ_អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ត្រូវទទួលបន្ទុកអនុវត្តន៍តាមប្រកាសនេះ អោយមានប្រសិទ្ធិភាពដោយសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ។

**ប្រការ៦:** ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៩ តទៅ

ចម-ប្រសិទ្ធ

**ចំលងជូន:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
-ក្រសួងសុខាភិបាល
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-គ្រប់សាលាខេត្ត-ក្រុង
-សភាពាណិជ្ជកម្ម
-គ្រប់មន្ទីរពាណិជ្ជកម្មខេត្ត-ក្រុង
-ឯកសារ-កាលប្បវត្តិ